ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ

# នីតិវិធីនៃការបង្កកទ្រព្យសម្បត្តិរបស់បុគ្គល និង អង្គភាព មានឈ្មោះក្នុង UNSCR

ឧ.ត្រី សេន សុភាព
អនុប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង និងជាអនុប្រធានក្រុមប្រតិបត្តិការផ្ទាល់

ថ្ងៃទី១២-១៣ ខែមិថុនា ឆ្នាំ២០២៤

# សេចក្តីផ្តើម

- **មូលហេតុនៃការរៀបចំច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ**
  - ការរីកសាយភាយអាវុធមហាប្រល័យជាការគំរាមកំហែងដល់សន្តិសុខពិភពលោកទាំងមូល
  - បំពេញនូវកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា
  - បំពេញចំណុចខ្វះខាតផ្នែកគតិយុត្ត
  - ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- **ដំណើរការរៀបចំច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ**
  - ក្រុមការងារអន្តរក្រសួង ដឹកនាំដោយក្រសួងមហាផ្ទៃ និងមានការគាំទ្រជំនួយបច្ចេកទេសពីអ្នកជំនាញការច្បាប់អូស្ត្រាលី នៃក្រុមជំនួយប្រឆាំងការសម្អាតប្រាក់នៃក្រសួងកិច្ចការផ្ទៃក្នុងអូស្ត្រាលី
  - សិក្ខាសាលារៀបចំរួមគ្នារវាងក្រសួងមហាផ្ទៃ និងស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ថ្ងៃទី៩-១០ ខែតុលា ឆ្នាំ២០១៩
  - ចាប់តាំងពីខែមករា ឆ្នាំ២០២០មក ក្រុមការងារបានប្រជុំពិភាក្សាជាបន្តបន្ទាប់ពិនិត្យលើសេចក្តីព្រាងបឋមដែលទទួលបានពីភាគីអូស្ត្រាលីនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩




ច្បាប់
ស្តីពី
ការប្រឆាំងហិរញ្ញប្បទាន
ដល់ការរីកសាយភាយអាវុធមហាប្រល័យ

អនុក្រឹត្យ
ស្តីពី
ការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កក
នៃហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

អនុក្រឹត្យ
ស្តីពី
បែបបទ និងនីតិវិធីនៃការអនុវត្តច្បាប់ស្តីពីការប្រឆាំង
ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

ប្រកាស
ស្តីពី
ទម្រង់នៃរបាយការណ៍អំពី
ការបង្កកទ្រព្យសម្បត្តិដែលត្រូវ
ធ្វើដោយបុគ្គលឬអង្គភាពក្រៅ
ពីបុគ្គលរាយការណ៍

# នីតិវិធីនៃការបង្កកទ្រព្យសម្បត្តិរបស់បុគ្គលនិងអង្គភាព

## ច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យ

### មាត្រា៦ ៖ ការបង្កកទ្រព្យសម្បត្តិ

រាល់បុគ្គលឬអង្គភាពដែលកំពុងកាន់កាប់ទ្រព្យសម្បត្តិដែលត្រូវបានបង្កកតាមអំណាចសេចក្តីសម្រេចរបស់តុលាការ ដូចបានកំណត់ក្នុងមាត្រា៤ឬមាត្រា៥នៃច្បាប់នេះ ត្រូវបង្កកទ្រព្យសម្បត្តិទាំងនោះដោយគ្មានបង្អង់ និងដោយគ្មានជូនដំណឹងជាមុនឡើយ។

## ច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យ

### មាត្រា១៤ ៖ ការរឹបអូសទ្រព្យសម្បត្តិបង្កក

*ការរឹបអូសទ្រព្យសម្បត្តិដែលត្រូវបានបង្កក ត្រូវអនុវត្តទៅតាមសេចក្តីសម្រេចរបស់តុលាការតាមសំណើពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឬពីព្រះរាជអាជ្ញាអមសាលាដំបូង បន្ទាប់ពីទទួលបានអធិបញ្ញារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឬផ្អែកតាមសំណើពីអ្នកកាន់កាប់ទ្រព្យសម្បត្តិដែលត្រូវបានបង្កក។

*តុលាការអាចចេញសេចក្តីសម្រេចបង្គាប់ឱ្យរឹបអូសទ្រព្យសម្បត្តិដែលត្រូវបានបង្កកប្រសិនបើមានហានិភ័យសមហេតុសមផលបង្ហាញថាទ្រព្យសម្បត្តិនោះអាចនឹងបាត់បង់។

*តុលាការអាចចាត់តាំងអ្នកគ្រប់គ្រងមើលចាត់ចែងទ្រព្យសម្បត្តិដែលបានរឹបអូស។

*ទ្រព្យសម្បត្តិដែលបានរឹបអូសស្របតាមមាត្រានេះ ត្រូវរក្សាទុកដោយគ្រប់គ្រងដែលតែងតាំងដោយតុលាការ រហូតដល់ពេលទ្រព្យសម្បត្តិនោះលែងជាកម្មវត្ថុនៃការបង្កកទ្រព្យសម្បត្តិដូចមានកំណត់ក្នុងមាត្រា៤ឬមាត្រា៥នៃច្បាប់នេះ

# នីតិវិធីនៃការបង្កកទ្រព្យសម្បត្តិរបស់បុគ្គលនិងអង្គភាព

**ក្រ.ការបរទេស...**

- ពី/ទៅ UNSC
- បញ្ជូនដោយគ្មានបង្អង់ទៅក្រ.យុត្តិធម៌

**ក្រ.យុត្តិធម៌**

- បញ្ជូនឯកសារដែលទទួលពីក្រ.ការបរទេសទៅសាលាដំបូងមានសមត្ថកិច្ចដោយគ្មានបង្អង់ដើម្បីស្នើសុំសេចក្តីសម្រេចបង្កកទ្រព្យ
- អាចសុំព័ត៌មាននិងភស្តុតាងពីគ្រប់ប្រភព
- អធិបញ្ញាឱ្យអគ្គ.អមសាលាឧទ្ធរណ៍ឬព្រះរាជអាជ្ញាអមសាលាដំបូង (ដាក់ឈ្មោះក្នុងបញ្ជី និងបង្កកទ្រព្យសម្បត្តិនិង/ឬរឹបអូស)

**តុលាការ**

- ដីកាសម្រេចបង្កកទ្រព្យសម្បត្តិដោយទុកជាការប្រញាប់ (ដីកាអចិន្ត្រៃយ៍)
- រឹបអូស (តាមសំណើរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឬព្រះរាជអាជ្ញាអមសាលាដំបូងឬសំណើពីអ្នកកាន់កាប់ទ្រព្យបង្កក)
- ទ្រព្យសម្បត្តិដែលរឹបអូសត្រូវរក្សាទុកដោយអ្នកគ្រប់គ្រងតែងតាំងដោយតុលាការ រហូតទ្រព្យនោះលែងជាកម្មវត្ថុនៃការបង្កក។

**បុគ្គលរាយការណ៍ (កាស៊ីណូ)**

- បង្កកគ្មានបង្អង់ គ្មានជូនដំណឹងមុន (គុក២-៥ឆ្នាំ)
- ក្នុង៣ថ្ងៃ ត្រូវរាយការណ៍ការបង្កក ទៅសហក (គុក១-៦ខែ)
- ដាក់ពាក្យសុំរឹបអូសទៅតុលាការ

**ស.ហ.ក.**

**គ.ល.ក.**

- ទទួល/បញ្ជូនបន្តទៅបុគ្គលរាយការណ៍
- ប្រឹក្សានីតិវិធីនានា

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ

# នីតិវិធីនៃការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិបង្កក

# នីតិវិធីនៃការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិបង្កក

## ច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទាន
## ដល់ការរីកសាយភាយអាវុធមហាប្រល័យ (២៧-មិថុនា-២០២០)

មាត្រា៩ ៖

បុគ្គលឬអង្គភាពដែលកាន់កាប់ទ្រព្យសម្បត្តិបង្កកអាចត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិបង្កកបាន។
ការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កកត្រូវកំណត់ដោយអនុក្រឹត្យ។

## អនុក្រឹត្យស្តីពី ការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កក
## នៃហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (៣០-កញ្ញា-២០២០)

មាត្រា៤ ៖

ត្រូវបានអនុញ្ញាតឱ្យបុគ្គលឬអង្គភាពដែលកាន់កាប់ទ្រព្យសម្បត្តិបង្កកអាចប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិបង្កកនោះតាមសេចក្តីសម្រេចរបស់តុលាការដើម្បីជានាៈ

-ការចំណាយមូលដ្ឋាន (ម. ៣ កថាខណ្ឌទី១)

-ការចំណាយលើការបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដែលបានធ្វើមុនការដាក់ទណ្ឌកម្ម (ម. ៣ កថាខណ្ឌទី២)

-ការចំណាយផ្សេងៗដែលទទួលបានការអនុញ្ញាតនិងស្របតាមសេចក្តីសម្រេចចិត្តនានារបស់ អ.ស.ប (ម. ៣ កថាខណ្ឌទី៣)

មាត្រា៥ ៖

បុគ្គលឬអង្គភាពដែលកាន់កាប់ទ្រព្យសម្បត្តិបង្កកត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់និង/ឬចាត់ចែងទ្រព្យសម្បត្តិដែលត្រូវបានបង្កកនោះទៅតុលាការដែលបានចេញសេចក្តីសម្រេចបង្កក។ សេចក្តីសម្រេចបង្កកត្រូវធ្វើឡើងជាទម្រង់ដីកាសម្រេច។

# នីតិវិធីនៃការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិបង្កក

- ការបង់ទឹក ភ្លើង សំរាម ម្ហូបអាហារ ហ្គាស
- បង់ពន្ធ ធានារ៉ាប់រង ថ្នាំពេទ្យ ព្យាបាលជម្ងឺ
- ឈ្នួលវិជ្ជាជីវៈ សេវាច្បាប់
- បង់ថ្លៃឈ្នួល ឬ ប្រាតិភោគ
- ចំណាយផ្សេងៗមិនរំលោភ UNSCR

**មូលដ្ឋាន**

**បំពេញកាតព្វកិច្ចតាមកិច្ចសន្យាមុនទណ្ឌកម្ម**

- អនុវត្តកិច្ចសន្យាមុនថ្ងៃទ្រព្យត្រូវបានបង្កក ហើយ
- ការបង់ថ្លៃនោះមិនរំលោភ UNSCR

- មិនរាប់ចូល មូលដ្ឋាន/បំពេញកាតព្វកិច្ចតាមកិច្ចសន្យាដែលកំណត់ដោយក្រ.យុត្តិធម៌ និងមិនរំលោភ UNSCR
- UNSC អនុម័ត

**អនុញ្ញាតពី UN**



# អរគុណ